**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

**ស្តីពី**

## ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត

**រវាង**

នាយករោងចក្រ និង ប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត

**កម្មវត្ថុ** សំណើសុំព្យួរកិច្ចសន្យាកាងារ កម្មករនិយោជិតចំនួន ៣៥៤ នាក់រយៈពេល៣១ថ្ងៃ។

**យោង** មាត្រា៧១ និងមាត្រា៧២ នៃច្បាប់ស្តីពីការងាររបស់ព្រះរាជាណាចក្រកម្ពុជា។

សេចក្តីណែនាំស្តីពីការព្យួរកិច្ចសន្យាការងារ សម្រាប់រោងចក្រ សហគ្រាសគ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារវិបត្តិសេដ្ឋកិច្ចសកល លេខ:០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃពុធ ៩រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មិនា ឆ្នាំ២០២៣ ។

ថ្ងៃទី២៤ ខែ វិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង១៥ និង៣០នាទី មានកិច្ចប្រជុំនៅរោងចក្រស៊ីកូ (ខេមបូឌា)ខូ អិល ធី ឌី

បានព្រមព្រៀង និងឯកភាពគ្នាដូចខាងក្រោម៖

១-ព្យួរកិច្ចសន្យាការងារកម្មករនិយោជិតផ្នែកដេរ ផ្នែកខ្សែទឹកហូរ ផ្នែកបិទភ្ជាប់ ផ្នែកអ៊ុតព្រីម ទាំងអស់សរុបចំនួន ៣៤៩ នាក់រយៈពេល ៣១ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០២៣។

២-នាយករោងចក្រ និងប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត បានព្រមព្រៀងផ្តល់ប្រាក់ចំនួន ៣០ ដុល្លារអាមេរិក ចំពោះកម្មករដែលព្យួរការងារបើកលុយរៀងរាល់ថ្ងៃទី១០ ខែ មករា ឆ្នាំ២០២៤ គឺបើកតាមធានាគារ អេស៊ីលីដា ។

៣-ចូលធ្វើការវិញនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ ។

កំណត់ហេតុនៃកិច្ចព្រមព្រៀងនេះ បានចប់សព្វគ្រប់នៅថ្ងៃ ខែ ឆ្នាំដដែលវេលាម៉ោង១៦ និង ០០នាទី ក្រោមបរិយាកាសរីករាយ ឯកភាពគ្នា និងភាពស្និទ្ធស្នាលក្រៃលែង។

បាវិត ថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ២០២៣

ស្នាមមេដៃស្តាំប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត

ហត្ថលេខា និងត្រា

YANG,TEH-CHEN